ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៤២ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ « ហ៊ុន សែន ត្បែង » ទៅជាវិទ្យាល័យ « ហ៊ុន សែន ត្បែង »
ស្ថិតនៅក្នុងឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ក្នុងឃុំត្បែង ស្រុកកំពង់ស្វាយ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ហ៊ុន សែន ត្បែង » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ហ៊ុន សែន ត្បែង » ស្ថិតនៅក្នុងឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

រ៉ុម សិទ្ធី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ធំ "ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឯ.មចទ

C:\New school\Increase-hs.doc